00894181

E189/3/1/7/Corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Mar-2013, 11:19
CMS/CFO: Sann Rada

# សំណើសុំការកែតម្រូវ

សំណុំរឿងលេខ៖ 002/19-09-2007-ECCC/TC

| កែលើឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| E189/3/1/7 | 00893610-00893634 | 19 March 2013 | ☐ កែលើឯកសារដើម<br>☒ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| មូលហេតុនៃការកែតម្រូវ៖ |
|---|
| នៅមានពាក្យមួយទៀតគួរតែកោសលុប |

| សេចក្តីលម្អិតនៃការកែតម្រូវ៖ |
|---|
| កោសលុបថែមមួយពាក្យទៀតលើ ERN 00893626 |

ភាគីស្នើសុំ៖ ក្រុមមេធាវីការពារក្តីលោក នួន ជា — ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ Theoun — ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ — ហត្ថលេខា៖

ករណី [redacted] មានហេតុផលគួរឱ្យជឿជាក់ថា គាត់មានភស្តុតាងដោះបន្ទុកដោយផ្ទាល់[32]។ ដោយសារតែសារៈសំខាន់យ៉ាងច្បាស់ក្រឡែតនៃសាក្សីទាំងពីរខាងលើ និងការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការផ្តល់មូលហេតុឱ្យបានគ្រប់គ្រាន់លើសេចក្តីសម្រេចរបស់ខ្លួនមិនព្រមស្តាប់សក្ខីកម្មរបស់ពួកគេ និងមិនព្រមទទួលយកសារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងការលំបាកក្នុងការទទួលបានការចូលខ្លួនរបស់សាក្សី

---

ប្រទេសកម្ពុជាក្រោមសម័យខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់៧៩, ឯកសារ ERN 00678476-00678740, ទំព័រ៣៨។ (អ្នកឧត្តរ បានត្រូវគេស្គាល់ថ្លាមដោយសារតែការប្រើវិធីសាស្ត្រកាចសាហាវរបស់ពួកគេជាងកម្លាំងនៅនិរតី និងនៅក្នុងភូមិភាគពិសេស),ទំព័រ៤៣។ ("អ្នកបូព៌ាប្រើវិធីសាស្ត្រត្រជាក់។ ពួកគេបានចែកថ្នាំពេទ្យ និងអង្ករជូនប្រជាជនតាមផ្លូវ"។ មិនដូចជាពួករនិរតីឡើយ ពួកគេមិនបាន បើកការប្រយុទ្ធគ្នាទេ... កម្លាំងនៅភូមិភាគបូព៌ាជាទូទៅមានអត្តចរិកល្អជាងគេ) ,ទំព័រ៤៧ (...គាត់យល់ឃើញ ថាពួកអារខ្មៅនៅភូមិភាគឧត្តរ ពិតជាកាចសាហាវចំពោះជនភៀសខ្លួនខ្លាំងណាស់ ។ នៅពេលជាមួយគ្នានោះ ពួកខ្មែរក្រហមទាំងនេះ បានរិះគន់យ៉ាងខ្លាំងដល់ពួកខ្មែរក្រហមដ៏ទៃទៀតដែលឈរជើងនៅត្រើយម្ខាងទៀតនៃស្ទឹងក្នុងភូមិភាគបូព៌ា...[ទាហាននៅបូព៌ា] ជួយយកអាសារប្រជាជនខ្លាំងណាស់... ពោលគឺទាហានចិត្តល្អ) ។ គ្មានបុគ្គលណាទៀតដែលបានដឹងអំពីទំនាក់ទំនងរវាងមជ្ឈិមបក្ស និងមេដឹកនាំភូមិភាគប្រហាក់ប្រហែលនឹង [redacted] ត្រូវបានពិចារណាយកជាសាក្សីសក្ខានុពលក្នុងសំណុំរឿង០០២ឡើយ (ករណីលើកលែងដែលអាចកើតឡើងតែមួយគត់គឺសាក្សី [redacted], ដែលជាជនសង្ស័យម្នាក់ក្នុងសំណុំរឿង០០៣ ដែលមិនត្រឹមតែទទួលបានការការពារពីរាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានសិទ្ធិនៅស្ងៀមផងដែរ)។ បុគ្គលទាំងពីររូបនេះគឺជាអ្នកដែលបានចូលរួមកិច្ចប្រជុំមួយដែលធ្វើឡើងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ ដែលគេនិយាយថាពាក់ព័ន្ធទៅនឹងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យទៅលើមន្ត្រីសាធារណៈរដ្ឋ។ ប៉ុន្តែបុគ្គលទាំងពីររូបនេះបានពិពណ៌នាកិច្ចប្រជុំនេះទៅកាន់លោក Ben Kiernan ថា៖ ផ្ទុយទៅវិញ [redacted] បានអះអាងថា នួន ជា បានបញ្ជាឱ្យ "កម្ទេច" មន្ត្រីសាធារណៈរដ្ឋ ប៉ុន្តែ [redacted] បានច្រានចោលការចងចាំបែបនេះ ហើយគាត់បានលើកឡើងថា នួន ជា បានប្រើឃ្លាខុសពីនេះ គឺគ្រាន់តែឱ្យគេ "វាយឱ្យខ្ចាត់ខ្ចាយ" តែប៉ុណ្ណោះ។ ដូច្នេះ សក្ខីកម្មរបស់ [redacted] ពិតជាភស្តុតាងដោះបន្ទុកដោយផ្ទាល់ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ប្រឆាំង នួន ជា ហើយបានផ្តល់ភស្តុតាងគាំទ្រទៅដល់ការអះអាងជាយូរមកហើយរបស់មេធាវីការពារក្តីដែលថាឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងគឺទទួលបញ្ជាពីមន្ត្រីថ្នាក់ក្រោម ឬគ្មានបញ្ជាអ្វីទាំងអស់។ ដូចដែលអង្គជំនុំជម្រះបានទទួលស្គាល់ដោយឥតសង្ស័យថាការចងចាំរបស់ [redacted] អំពីកិច្ចប្រជុំនេះ គឺមិនត្រឹមតែពាក់ព័ន្ធទៅនឹងកិច្ចប្រជុំនេះដោយផ្ទាល់ទេ ប៉ុន្តែវាក៏អាចបង្កើតជាសំនួរមួយផងដែរៈតើគាត់ស្គាល់នរណាទៀតក្នុងកិច្ចប្រជុំនោះ? ដោយសារតែគាត់បដិសេធមិនព្រមសហការជាមួយតុលាការ ដូច្នេះ សំណួរនេះ គ្មានចម្លើយឡើយ។

[32] សំណើសុំកោះហៅសាក្សីរបស់ នួន ជា, កថាខណ្ឌ៣៣ ដល់៣៤។

Formatted: Highlight